+855 (0)17 774864
www.sasabassac.com

#18 (upstairs) Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សស-សាបាសាក់ SA SA BASSAC

# រណ្ដៅបេ
## ដោយ  វណ្ឌី រតនា

“មានពាក្យចាស់ខ្មែរមួយឃ្លានិយាយថា ឮ ១000 ដង មិនស្មើឃើញ ១ ដង។” - វណ្ឌី រតនា

នៅចន្លោះឆ្នាំ ១៩៦៤ ដល់ ១៩៧៥ កងទ័ពសហរដ្ឋអាមេរិកបានធ្វើការទម្លាក់គ្រាប់បែក ចំនួន ២,៧៥៦,៩៤១ តោន (២៣០,៥១៦ ដង លើ ១១៣,៧១៦ ទីកន្លែង) មកលើប្រទេសកម្ពុជា ដែលជាប្រទេសមួយប្រកាន់យកគោលនយោបាយអព្យាក្រឹត ។ តួលេខនេះមិនត្រូវបានគេទទួលស្គាល់ទេរហូតមកទល់ឆ្នាំ ២000 គឺនៅពេលដែលលោកអតីតប្រធានាធិបតី ប៊ីល គ្លីនតុន បានមកធ្វើទស្សនកិច្ចនៅប្រទេសវៀតណាម ហើយបានបង្ហើបដោយស្ងៀមស្ងាត់នូវទិន្នន័យរបស់កងទ័ពអាកាស ស្ដីអំពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើអតីតតំបន់ឥណ្ឌូចិន ។

ដោយមិនពេញចិត្តចំពោះកង្វះខាតនៃការធ្វើកំណត់ត្រាឯកសារស្ដីពីបញ្ហានេះ វណ្ឌី រតនា បានធ្វើដំណើរទៅកាន់ខេត្តចំនួន ១០ ក្នុងប្រទេសកម្ពុជាដែលបានទទួលរងការទម្លាក់គ្រាប់បែកធ្ងន់ធ្ងរជាងគេពីយុទ្ធនាការកងទ័ពរបស់សហរដ្ឋអាមេរិក នៅក្នុងអំឡុងពេលសង្គ្រាមវៀតណាម ។ នៅក្នុងការធ្វើដំណើរនេះ រតនាបានបង្កើតទំនាក់ទំនងជាមួយអ្នកភូមិក្នុងការស្វែងរកទីតាំង និងផ្ដល់សក្ខីកម្មអំពីវត្តមាននៃរណ្ដៅជាច្រើនដែលកកើតឡើងដោយសារការទម្លាក់គ្រាប់បែក ដែលត្រូវបានហៅជាភាសាខ្មែរថា “រណ្ដៅបេ” ។

លទ្ធផលនៃស្នាដៃនេះគឺជា កំរងរូបថតទេសភាពដ៏ស្ងៀមស្ងាត់ និងអាថ៌កំបាំងចំនួន ៩ រូប រួមជាមួយនិងខ្សែភាពយន្តឯកសារមួយ ដែលក្នុងនោះអ្នកភូមិរៀបរាប់ពីការចងចាំរបស់ពួកគាត់អំពីការទម្លាក់គ្រាប់បែក និងទំនាក់ទំនងបច្ចុប្បន្នរបស់ពួកគេជាមួយនិងរណ្ដៅបេទាំងនោះ ។ “រណ្ដៅបេ” អនុញ្ញាតអោយទស្សនិកជនស្វែងយល់អំពីភាពផុយស្រួយនិងស្មារតីរស់រានឡើងវិញរបស់ប្រជាជននិងទឹកដី និងអោយទស្សនិកជនពិចារណាសារជាថ្មីនូវប្រវត្តិសាស្ត្រ នៃសកម្មភាពរបស់សហរដ្ឋអាមេរិកក្នុងអំឡុងពេលសង្គ្រាមវៀតណាម និងសកម្មភាពនៃអំពើហិង្សានានាស្រដៀងគ្នានេះនៅទូទាំងពិភពលោក ។

រតនា កើតនៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៨០ ដែលជាសម័យដ៏ផុយស្រួយ ខណៈពេលដែលកម្ពុជាទើបតែងើបពីរបបខ្មែរក្រហម ។ រតនា បារម្ភពីកង្វះខាតនៃកំណត់ត្រាឯកសារស្ដីពីរឿងរ៉ាវ ចរិតលក្ខណៈ និងទីកន្លែងប្រវត្តិសាស្ត្រដែលមានលក្ខណៈដោយឡែកចំពោះវប្បធម៌របស់គាត់ ។ កំរងស្នាដៃរូបថតរបស់គាត់ ត្រូវបានថតផ្ដិតដោយប្រើម៉ាស៊ីនថតប្រើហ្វីលជាច្រើនប្រភេទ ហើយរួមបញ្ចូលគ្នារវាងរូបថតបែបសារព័ត៌មាននិងការងារបែបសិល្បៈ។ លក្ខណៈនៃប្រធានបទស្នាដៃរបស់គាត់ ភាគច្រើនជំរុញទៅលើសពីការធ្វើកំណត់ត្រាឯកសារដ៏ច្រើនលើសលប់ដែលរំខានដល់ការអភិវឌ្ឍរបស់កម្ពុជា ហើយបង្កើតទំនាក់ទំនងដ៏សំខាន់ៗរវាងរឿងរ៉ាវបច្ចុប្បន្ន និងគុណតម្លៃប្រវត្តិសាស្ត្រដែលដក់ជាប់នៅក្នុងកំណត់ត្រាជាហូរហែរក្នុងសម័យសព្វថ្ងៃ ។

*ពិព័រណ៍សំរាំងមួយចំនួនរបស់ វណ្ឌី រតនា* ៖ “រណ្ដៅបេ”, សារមន្ទីរ Hessel, ទីក្រុងញូយ៉ក(២០១០); “អគ្គីភ័យប្រចាំឆ្នាំ”, ពិព័រណ៍សិល្បៈសហសម័យអាស៊ីប៉ាស៊ីហ្វិក សំរាប់ ៣ ឆ្នាំម្ដងលើកទី ៦, ទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី (២០០៩); “ដំណើរឆ្លងកាត់”, វិចិត្រសាលស-ស, ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា (២០០៩) “TADAIMA: ស្វែងរកផ្ទះដ៏គួរ អោយស្រលាញ់”, សកលវិទ្យាល័យយូស៊ូ, ប្រទេសជប៉ុន (២០០៩); “Magnetic Power”, មណ្ឌលកូរ៉េ-អាស៊ាន, ប្រទេសកូរ៉េ (២០០៩); “តាំងពីកាលនោះមកទល់បច្ចុប្បន្ន៖ សិល្បៈ សហសម័យមកពីប្រទេសកម្ពុជា”, វិចិត្រសាល 10 Chancery Lane, ទីក្រុងហុងកុង (២០០៩); “អាស៊ីមួយផ្សេងទៀត”, ពិព័រណ៍រូបថត Noorderlicht, ប្រទេសហូឡង់ (២០០៦) ។

# The Bomb Ponds
## Vandy Rattana

*There is a Khmer proverb that says: You can hear something a thousand times and not know it, yet if you see it with your eyes just once, you know.*
- Vandy Rattana

Between 1964 and 1975 the United States of America military dropped 2,756,941 tons (230,516 sorties on 113,716 sites) of bombs across politically neutral Cambodia. This figure went unacknowledged until 2000 when Bill Clinton traveled to Vietnam and quietly released previously classified Air Force data on American bombings in former Indochina.

Dissatisfied with the level of documentation produced on the subject, Vandy Rattana traveled to the ten Cambodian provinces most severely bombed in the U.S. military campaign during the Vietnam War. Along the way, he engaged villagers in locating and testifying to the existence of the craters made by the bombings, known in the Khmer language as the “bomb ponds”.

The resultant work is a series of nine quiet, mysteriously serene landscape photographs and a confronting one-channel documentary film in which villagers describe their memories of the bombings as well as their relationship to the ponds today. The Bomb Ponds invites audiences to connect with both the fragility and the resilience of the people and the land, and to reconsider the historical thread of America's actions during the Vietnam War and subsequently, similar acts of violence worldwide.

Born into the tenuous recovery period after the official fall of the Khmer Rouge, Vandy Rattana (b.1980 Phnom Penh) is concerned with the lack of physical documentation accounting for the stories, traits, and monuments unique to his culture. His serial work employs a range of analog cameras and formats, straddling the line between strict photojournalism and artistic practice. The extensive nature of his subject matter forges against the plethora of stymied documentation on Cambodia today, and makes critical connections between present-day narratives and the historical value inherent in chronicling the contemporary moment.

Selected exhibitions by Vandy Rattana:
*The Bomb Ponds*, Hessel Museum, NY (2010); *Fire of the Year*, The 6th Asia Pacific Triennial of Contemporary Art (APT6), Brisbane, Australia (2009); *Walking Through*, Sa Sa Art Gallery, Phnom Penh, Cambodia (2009); *TADAIMA: Looking for Sweet Home*, Kyushu University, Japan (2009); *Magnetic Power*, Asean-Korean Center, Seoul, Korea (2009); *Forever Until Now: Contemporary Art From Cambodia*, 10 Chancery Lane Gallery, Hong Kong (2009); *Another Asia*, Noorderlicht Photo Festival, The Netherlands (2006).

# រណ្ដៅបេ
## ដោយ  វណ្ឌី រតនា

# The Bomb Ponds
## Vandy Rattana

17 February through 20 March 2011



*Kompong Thom*, 2009, Digital C-Print, 90x105cm



*The Bomb Ponds film*, (single-channel, 23 minutes), Hessel Museum, NY, 2009.